# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០៤

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីអំពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី.
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់ពេលបំរើការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ លេខ ១៦០/២០០៣/គ.ប.ជ.អ ចុះថ្ងៃទី ០១ សីហាឆ្នាំ ២០០៣ ។

## សម្រេច

__មាត្រា១__ : អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សម្រាកការងារប្រចាំឆ្នាំ ២០០៤ តាមប្រតិទិនដូចខាងក្រោម :

| | | | |
|---|---|---|---|
| - ថ្ងៃទី០១ | មករា | ទិវាចូលឆ្នាំសកល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៧ | មករា | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៥ | កុម្ភៈ | ទិវាបុណ្យមាឃបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៨ | មីនា | ទិវានារីអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី១៣-១៤-១៥ | មេសា | ទិវាចូលឆ្នាំខ្មែរប្រពៃណីជាតិ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី០១ | ឧសភា | ទិវាពលកម្មអន្តរជាតិ | សម្រាក ០១ ថ្ងៃ |

| | | | |
|---|---|---|---|
| - ថ្ងៃទី០៣ | ឧសភា | ទិវាបុណ្យវិសាខបូជា | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០៧ | ឧសភា | ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី០១ | មិថុនា | ទិវាកុមារអន្តរជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី១៨ | មិថុនា | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេច ព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី២៤ | កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី ១២-១៣-១៤ | តុលា | បុណ្យភ្ជុំបិណ្ឌ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី២៣ | តុលា | ទិវាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី៣០-៣១តុលា និង ០១វិច្ឆិកា | | ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ | សម្រាក ០៣ថ្ងៃ |
| - ថ្ងៃទី០៩ | វិច្ឆិកា | ទិវាបុណ្យឯករាជ្យជាតិ | សម្រាក ០១ ថ្ងៃ |
| - ថ្ងៃទី២៥-២៦-២៧ | វិច្ឆិកា | ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែនិងអកអំបុក | សម្រាក ០៣ ថ្ងៃ |
| - ថ្ងៃទី១០ | ធ្នូ | ទិវាសិទ្ធិមនុស្សអន្តរជាតិ | សម្រាក ១ ថ្ងៃ |

**មាត្រា២:** ពេលវេលាឈប់សម្រាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំងពីរ ថ្ងៃជាប់គ្នា គឺ ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវអនុញ្ញាតអោយឈប់សម្រាកបន្ថែមជាជំនួស គឺឈប់តែ ០១ ថ្ងៃប៉ុណ្ណោះ ។

**មាត្រា៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ